សលាកប័ត្រព័ត៌មាន៖ សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន ("សេចក្តីប្រកាស")
កាលបរិច្ឆេទ៖ នឹងត្រូវអនុម័តក្នុងខែវិច្ឆិកា ឆ្នាំ២០១២
ការធ្វើចំណាត់ថ្នាក់របស់ម.ស.ម.ក៖ ពណ៌លឿង (លក្ខខណ្ឌធម្មតាដែលត្រូវបានអនុវត្តចំពោះច្បាប់តំបន់ជាជាងច្បាប់កម្ពុជា)
ចំណុចរួម៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានធ្វើចំណាត់ថ្នាក់ពណ៌លឿងចំពោះសេចក្តីព្រាងនៃសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ានដែលត្រូវបានបែកធ្លាយ៖ ទស្សនៈជាមូលដ្ឋាននៃសេចក្តីប្រកាសនេះ គឺមានលក្ខណៈល្អប្រសើរ ប៉ុន្តែទោះជាយ៉ាងណាក្តី មាត្រាមួយចំនួននៃសេចក្តីប្រកាសនេះមានលក្ខណៈប្រឆាំងគ្នានឹងគោលបំណងដែលបានលើកឡើងក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សនៅក្នុងសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ("អាស៊ាន")។ សេចក្តីប្រកាស – ដែលមានការប្រឹក្សាដោយពេញលេញ និងប្រកបដោយតម្លាភាព ជាមួយនឹងសង្គមស៊ីវិលអាស៊ាន – ត្រូវតែពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ដើម្បីធានាថាឯកសារគោលនេះ បង្កើតបទដ្ឋានសិទ្ធិមនុស្ស ដូចដែលបានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស") និងកតិកាអន្តរជាតិទាំងឡាយដែលអាចយកមកអនុវត្តបាន។ លើសពីនេះទៅទៀត សេចក្តីប្រកាសនេះគួរផ្តល់នូវយន្តការអនុវត្តពហុរដ្ឋមួយប្រកបដោយប្រសិទ្ធិភាព ដើម្បីដោះស្រាយករណីរំលោភសិទ្ធិមនុស្ស។



សេចក្តីផ្តើម

សលាកប័ត្រនេះផ្តល់ជាទស្សនៈសង្ខេបមួយ ទាក់ទងនឹងសេចក្តីព្រាងសេចក្តីប្រកាស ដែលត្រូវបានបែកធ្លាយនាពេលថ្មីៗនេះ ហើយដែលឥឡូវនេះកំពុងត្រូវបានធ្វើសេចក្តីព្រាងដោយគណៈកម្មាធិការអន្តររដ្ឋាភិបាលទទួលបន្ទុកសិទ្ធិមនុស្សអាស៊ាន ("គ.អ.រ.ស.អ") ហើយនឹងត្រូវអនុម័តនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ នៅក្នុងកិច្ចប្រជុំបូកសរុបនៃកិច្ចប្រជុំកំពូលអាស៊ានប្រចាំឆ្នាំ។ សេចក្តីប្រកាសនេះមានតួនាទីជាលិខិតបទកណ្ឌមូលដ្ឋានមួយ ដែលនឹងបង្កលក្ខណៈងាយស្រួលដល់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន នៃប្រជាពលរដ្ឋអាស៊ាន។ សលាកប័ត្រនេះត្រូវបានតាក់តែងឡើងដោយ ម.ស.ម.ក ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

សេចក្តីព្រាងនៃសេចក្តីប្រកាសដែលត្រូវបានបែកធ្លាយ – សេចក្តីសង្ខេប

សេចក្តីព្រាងនៃសេចក្តីប្រកាសដែលត្រូវបានបែកធ្លាយ មានបទប្បញ្ញត្តិវិជ្ជមានមួយចំនួន ដែលមានគោលដៅលើកកម្ពស់ និងការពារសិទ្ធិមនុស្ស នៃប្រជាពលរដ្ឋអាស៊ាន៖ ដាក់បញ្ចូលបទប្បញ្ញត្តិដែលចែងថាសាជីវកម្មមានទំនួលខុសត្រូវចំពោះការគោរពសិទ្ធិមនុស្ស (មាត្រា២៤) បទប្បញ្ញត្តិដែលមានបំណងការពារអ្នកការពារសិទ្ធិមនុស្ស ពីការដាក់ទណ្ឌកម្ម ឬការយាយីដោយបំពាន (មាត្រា៩៣) និងកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសថៃ ដើម្បីការពារអំពើហឹង្សាប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ និងស្ត្រី (មាត្រា២ និង៨១) ជាបទប្បញ្ញត្តិដែលប្រកបដោយភាពវិជ្ជមាន ដែលមិនត្រឹមតែត្រូវបានស្វាគមន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញថាសហគមន៍អាស៊ានមានសក្តានុពលក្នុងការដឹកនាំតាមមាគ៌ាលើកកម្ពស់ និងការពារសិទ្ធិមនុស្សទៀតផង។ លើសពីនេះទៅទៀត សេចក្តីព្រាងនៃសេចក្តីប្រកាសនេះ ក៏មានទិសដៅការពារសិទ្ធិសេដ្ឋកិច្ច (មាត្រា៦១–៦៧) សង្គមកិច្ច និងវប្បធម៌ (មាត្រា៦៨–៧០) នៃប្រជាពលរដ្ឋអាស៊ាន ហើយខ្លឹមសារនៃបទប្បញ្ញត្តិជាក់លាក់មួយចំនួន មានគោលបំណងការពារក្រុមជនងាយរងគ្រោះនៅក្នុងសង្គម ជាពិសេសស្ត្រី កុមារ និងជនចាស់ជរា (មាត្រា៨១–៩០)។

ក៏ប៉ុន្តែ ទោះបីជាមានវត្តមាននៃបទប្បញ្ញត្តិវិជ្ជមានដូចដែលបានរៀបរាប់ខាងលើនេះក៏ដោយ ក៏សេចក្តីប្រកាសនេះមានផ្ទុកមាត្រាមួយចំនួនដែលបណ្តាលឲ្យមានក្តីព្រួយបារម្ភផងដែរ។ ទីមួយ ដោយហេតុថាមានមាត្រាមួយចំនួនអាចនឹងត្រូវបានគេយកទៅប្រើប្រាស់ដើម្បីផ្សារភ្ជាប់សិទ្ធិរបស់រដ្ឋលើសពីសេរីភាព និងសិទ្ធិជាសកល៖ មាត្រា១៦ចែងថា ការអនុវត្តន៍សិទ្ធិមនុស្សត្រូវតែធ្វើការពិចារណានៅក្នុងបរិបទនៃ *"លក្ខណៈពិសេសរបស់ជាតិ និងតំបន់"* មាត្រា២៦ អនុញ្ញាតឲ្យរដ្ឋជាសមាជិក អាចធ្វើនាវាកណ៌កាតព្វកិច្ចរបស់ខ្លួនក្នុងការគោរពសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋខ្លួន ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវនៃ *"សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការពារសិទ្ធិ និងសេរីភាពនៅក្នុងសង្គមប្រជាធិបតេយ្យ"*។ ការប្រើប្រាស់វាក្យស័ព្ទ ដែលមានន័យមិនច្បាប់លាស់ក្នុងមាត្រាទាំងពីរនេះបណ្តាលឲ្យមានក្តីព្រួយបារម្ភថា រដ្ឋនឹងប្រើប្រាស់បទប្បញ្ញត្តិបែបនេះ ដើម្បីធ្វើឲ្យការរំលោភសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន នៃប្រជាពលរដ្ឋរបស់គេស្របច្បាប់។ លើសពីនេះទៅទៀត មានកិច្ចខិតខំប្រឹងប្រែងជាច្រើន ដើម្បីផ្តួចផ្តើមគុណវុឌ្ឍ ទៅលើមាត្រាមួយចំនួនដែលនឹងអាចបណ្តាលឲ្យមានការរឹតត្បិតសេរីភាពជាមូលដ្ឋាននៃសាសនា (មាត្រា៤៦) សេរីភាពបញ្ចេញមតិ និងយោបល់ (មាត្រា៤៧) និងសិទ្ធិប្រជាពលរដ្ឋក្នុងការចូលរួមដោយសេរី នៅក្នុងរដ្ឋាភិបាលនៃប្រទេសនីមួយៗ (មាត្រា៥៦)។

ម.ស.ម.ក ធ្វើចំណាត់ថ្នាក់ច្បាប់នីមួយៗ ដោយផ្អែកលើភាពអាចទទួលយកបាន និងអនុលោមទៅតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិ និងអន្តរជាតិ ដែលមានជាធរមាន។ ច្បាប់ទាំងឡាយណាដែលត្រូវបានធ្វើចំណាត់ថ្នាក់ពណ៌ខៀវ គឺមានន័យថា អាចទទួលយកបានតាមទស្សនៈរបស់ម.ស.ម.ក។ ច្បាប់ដែលត្រូវបានធ្វើចំណាត់ថ្នាក់ពណ៌លឿង គឺមានផ្ទុកនូវការព្រួយបារម្ភមួយចំនួនដែលត្រូវធ្វើការពិនិត្យឡើងវិញ និងត្រូវតែធ្វើវិសោធនកម្ម។ ដោយឡែកច្បាប់ដែលត្រូវធ្វើចំណាត់ថ្នាក់ពណ៌ក្រហម គឺជាច្បាប់ដែលមានលក្ខណៈធ្ងន់ធ្ងរជ្រុលហួសហេតុ ដោយរំលោភរដ្ឋធម្មនុញ្ញនិង/ឬច្បាប់អន្តរជាតិ និងច្បាប់ជាតិដែលមានជាធរមាន និង/ឬដោយមិនបានធ្វើការសាកល្បងគោលការណ៍សិទ្ធិមនុស្ស ដូច្នេះត្រូវតែបដិសេធចោល ទុកជាមោឃៈ ឬតាក់តែងឡើងវិញឲ្យបានសមស្រប។

ការរឹតត្បិតបែបនេះ គឺស្មើនឹងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋជាសមាជិកជាក់លាក់មួយចំនួន ដើម្បីកាត់បន្ថយវិសាលភាពនៃការអនុវត្តន៍សេចក្តីប្រកាស និងជាការបង្ហាញថាសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋអាស៊ានគឺសំខាន់តិចជាងសិទ្ធិរបស់រដ្ឋជាសមាជិក ។ ប្រសិនបើបទប្បញ្ញត្តិរឹតត្បិតនេះត្រូវបានបញ្ចូលទៅក្នុងសេចក្តីប្រកាសស្តាពរ អាស៊ាននឹងអាចប្រថុយនឹងការធ្លាក់ក្រោមបទដ្ឋានសិទ្ធិមនុស្សអប្បបរមាដែលកំណត់ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាអន្តរជាតិពាក់ព័ន្ធទាំងឡាយ ដែលរដ្ឋជាសមាជិក (ដូចជាកម្ពុជា) ចុះហត្ថលេខាទទួលស្គាល់ ។ បន្ថែមពីលើនោះទៀត សេចក្តីប្រកាសនេះ ប្រហែលជាអាចត្រូវបានរដ្ឋជាសមាជិកទទួលស្គាល់ជំនួសសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សក៏ថាបាន ។ ប្រសិនបើសេចក្តីប្រកាសស្តាពរ ធ្លាក់ក្រោមកម្រិតបទដ្ឋានសិទ្ធិមនុស្សអប្បបរមា ដែលបានកំណត់ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សមែននោះ ស្ថានភាពសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋអាស៊ាននឹងស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរជាងកាលពីមុនពេលដែលសេចក្តីប្រកាសនេះត្រូវបានអនុម័តទៅទៀត ហើយនេះជាភ័យន្តរាយមកលើអនាគតរបស់សិទ្ធិមនុស្សក្នុងតំបន់នេះ ។

ការអនុវត្ត?

បើទោះជាសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សផ្តោតការយកចិត្តទុកដាក់លើសិទ្ធិមនុស្សជាជំហានដ៏វិជ្ជមានមួយ ប៉ុន្តែសេចក្តីប្រកាសនេះគ្រាន់តែជាជំហានពាក់កណ្តាលទីមួយដោយសារតែសេចក្តីប្រកាសនេះមិនមានលក្ខណៈចាប់បង្ខំ។ ដោយសារតែបច្ចុប្បន្នមិនមានបទប្បញ្ញត្តិណាចែងពីការបង្កើតយន្តការអនុវត្តប្រកបដោយប្រសិទ្ធភាព ដែលបុគ្គលធម្មតាអាចទាមទារឲ្យភាគីដូចជា រដ្ឋាភិបាល និងសាជីវកម្ម ទទួលខុសត្រូវចំពោះករណីរំលោភសិទ្ធិមនុស្សរបស់ខ្លួន ។ ប្រសិនបើគ្មានការអនុវត្តយន្តការនេះ ដែលយើងអាចហៅម្យ៉ាងបានទៀតគឺ តុលាការសិទ្ធិមនុស្សថ្នាក់តំបន់ នោះសេចក្តីប្រកាសនឹងគ្មានអំណាច ហើយអាចធ្វើឲ្យមានការប៉ះពាល់ដល់សិទ្ធិបុគ្គលគ្រប់រូបដែលគួរតែត្រូវបានការពារដោយសេចក្តីប្រកាសនេះ ។ កង្វះខាតនៃយន្តការអនុវត្តប្រកបដោយប្រសិទ្ធភាព មានមូលហេតុចម្បងគឺការខ្វះខាតឆន្ទៈផ្នែកនយោបាយរបស់អាស៊ាន ក្នុងការជ្រៀតជ្រែកក្នុងអធិបតេយ្យភាព និងកិច្ចការផ្ទៃក្នុងរបស់រដ្ឋជាសមាជិក ។ រដ្ឋជាសមាជិកអាស៊ាននៅតែបន្តគិតថាអធិបតេយ្យភាពគឺមានលក្ខណៈដាច់ខាត និងហាក់ដូចជាមិនមានឆន្ទៈក្នុងការអនុញ្ញាតឲ្យអ្នកដទៃលូកដៃក្នុងអធិបតេយ្យភាពរបស់ខ្លួន ដើម្បីបង្កើតនូវយន្តការអនុវត្តប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀងដែលអនុញ្ញាតឲ្យមានការវិនិច្ឆ័យលើករណីរំលោភសិទ្ធិមនុស្សក្នុងសហគមន៍ទាំងមូល ។

ដំណើរការធ្វើសេចក្តីព្រាង និងកច្ចពិភាក្សាយោបល់

ចាប់តាំងពីពេលចាប់ផ្តើម សេចក្តីប្រកាសនេះត្រូវបានព្រាងឡើងនៅខាងក្រោយទ្វារដែលបិទជិតមួយ គឺចាត់ទុកជារឿងដ៏អាថកំបាំងខ្លាំងណាស់ ដែល គ.អ.រ.ស.អ គ្មានបំណងធ្វើការពិភាក្សា ឬក៏សហការណ៍ជាមួយសង្គមស៊ីវិលក្នុងអំឡុងការធ្វើសេចក្តីព្រាងនោះទេ ។ ទោះបីជាមានការខិតខំប្រឹងប្រែងពីរដ្ឋាភិបាលរបស់ប្រទេសថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងហ្វីលីពីន ក្នុងការធ្វើការរួមជាមួយអង្គការសង្គមស៊ីវិលក្នុងកម្រិតជាតិ ប៉ុន្តែជាទូទៅយើងឃើញថាមានកិច្ចពិភាក្សាតិចតួចបំផុត ដែលមិនគ្រប់គ្រាន់ ឬក៏សំក្តិសមសម្រាប់សេចក្តីប្រកាសដែលមានសារៈសំខាន់កម្រិតនេះនៅថ្នាក់តំបន់ ដែលទាមទារឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ ។ ដំណើរការធ្វើសេចក្តីព្រាងគួរតែមានតម្លាភាពពេញលេញ និងគួរតែមានការពិភាក្សាយ៉ាងបើកទូលាយនៅថ្នាក់តំបន់ ដើម្បីធានាថាការព្រួយបារម្ភរបស់ប្រជាពលរដ្ឋអាស៊ានទាំងស្រុងត្រូវបានឆ្លុះបញ្ចាំងក្នុងសេចក្តីប្រកាសជាស្តាពរ ហើយសិទ្ធិរបស់ពួកគេត្រូវបានការពារ ។ ម.ស.ម.ក អំពាវនាវឲ្យមានការរៀបចំកិច្ចពិភាក្សារបស់សង្គមស៊ីវិលទូទាំងតំបន់យ៉ាងឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន ដើម្បីពិភាក្សាលើសេចក្តីព្រាងដែលបែកធ្លាយនេះ ។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ទោះបីជាការស្នើសុំឲ្យមានបទប្បញ្ញត្តិស្តីពីសិទ្ធិមនុស្សនៅកម្រិតតំបន់នៅក្នុងសេចក្តីប្រកាសនេះ ចាត់ទុកជាជំហានដ៏គួរឲ្យស្វាគមន៍មួយក៏ប៉ុន្តែនៅតែមានការព្រួយបារម្ភមួយចំនួន ពាក់ព័ន្ធទាំងដំណើរការធ្វើសេចក្តីព្រាង និងខ្លឹមសារក្នុងសេចក្តីប្រកាសផ្ទាល់ ដែលតម្រូវឲ្យមានការលើកយកមកពិភាក្សាមុនពេលដែលសេចក្តីប្រកាសនេះត្រូវបានទទួលស្គាល់ថាពិតជាអាចលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពមូលដ្ឋាននៅក្នុងសហគមន៍អាស៊ាន ។ ម.ស.ម.ក អំពាវនាវឲ្យ គ.អ.រ.ស.អ ធានាថាដំណើរការធ្វើសេចក្តីព្រាងគឺពិតជាមានតម្លាភាពពេញលេញ ហើយដែលការខិតខំប្រឹងប្រែងនេះត្រូវបានធ្វើឡើងដើម្បីឲ្យមានការចូលរួមពីសង្គមស៊ីវិលនៅថ្នាក់តំបន់ ដើម្បីធានាថាសេចក្តីប្រកាសនេះ ឆ្លុះបញ្ចាំងពីក្តីព្រួយបារម្ភរបស់ប្រជាពលរដ្ឋអាស៊ាន ។ មិនត្រឹមតែប៉ុណ្ណោះ គ.អ.រ.ស.អ ត្រូវតែធានាថាសេចក្តីប្រកាសនេះមិនស្ថិតនៅទាបជាងបទដ្ឋានអប្បបរមានៃការគោរពសិទ្ធិមនុស្សដែលកំណត់ដោយ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិដែលពាក់ព័ន្ធផ្សេងៗ។ ផ្ទុយទៅវិញ គ.អ.រ.ស.អ គួរតែអនុម័តវិធានការជឿនលឿនមួយ ដើម្បីបង្ហាញថាតំបន់នេះអាចធ្វើជាគំរូក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស ។ ជាចុងក្រោយ ដើម្បីឲ្យសេចក្តីប្រកាសនេះមានប្រសិទ្ធភាព សេចក្តីប្រកាសនេះត្រូវតែមានបទប្បញ្ញត្តិមួយដើម្បីបង្កើតយន្តការអនុវត្តពហុរដ្ឋក្នុងតំបន់ ព្រោះថាប្រសិនបើគ្មានយន្តការបែបនេះ សេចក្តីប្រកាសនេះនឹងគ្មានប្រសិទ្ធភាពឡើយ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក អ៊ូ វីរៈ (+៨៥៥ (0) ១២ ៤០ ៤០ ៥១ ឬអ៊ីម៉ែលៈ ouvirak@cchrcambodia.org

ឬលោក រ៉ូប៊ឺត ហ្វីនស៍ (+៨៥៥ (0) ៧៨ ៨០ ៩៩ ៦០ ឬអ៊ីម៉ែលៈ robert.finch@cchrcambodia.org**។**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

CC BY NC SA